**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងរដ្ឋប្បវេណីលេខ ២១៤

ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

-សាលក្រមលេខ: ១៣ (គ)

ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣

ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ស្ពឺ

-ដើមចោទ និងជាចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted]បញ្ញាសក្កដា ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៤០៣៣២២៧០២ មុខរបរមន្ត្រីរាជការ អាសយដ្ឋានបច្ចុប្បន្ន [redacted]

-ចុងចម្លើយ និងជាដើមចោទនៃបណ្តឹងតបឈ្មោះ [redacted]សោភា ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០៤៧៧៧៥៨ (១) មុខរបរមេផ្ទះ អាសយដ្ឋានបច្ចុប្បន្ន [redacted]

-ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងជាដើមចោទនៃបណ្តឹងតបឈ្មោះ [redacted]សោភា។

**អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារនៃសាលក្រមដែលតាគីទាមទារ៖**

ក.កម្មវត្ថុនៃបណ្តឹងដើម

១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted]សោភា។

២-សម្រេចឱ្យចុងចម្លើយឈ្មោះ [redacted] សោភា មានសិទ្ធិលើទ្រព្យសម្បត្តិ ផ្ទះមួយល្វែង ទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៤ភូមិរំដួលជើង សង្កាត់ស្ពោ ខណ្ឌកំបូល រាជធានីភ្នំពេញ។

៣-សម្រេចឱ្យចុងម្លើយមានសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ ប្រិម ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩។

៤-សុំបង់សោហ៊ុយចាំបាច់ចិញ្ចឹមកូនប្រចាំខែទៅតាមលទ្ធភាព។

៥-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ដើមចោទ។

ខ.កម្មវត្ថុនៃបណ្តឹងតប

១-សុំលែងលះពីចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted]បញ្ញាសក្កដា។

២-បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបបង់ប្រាក់ចំនួន ២៨,០០០$(ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក មកឱ្យដើមចោទនៃបណ្តឹងតប ដោយប្រគល់ផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៨ភូមិវិជ្ជលជើង សង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ ទៅឱ្យចុងចម្លើយនៃបណ្តឹងតប។

៣-ប្រគល់សិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩ មកឱ្យដើមចោទនៃបណ្តឹងតប។

៤-បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន)រៀល ក្នុងមួយខែជារៀងរាល់ខែមកឱ្យដើមចោទនៃបណ្តឹងតបតាមរយៈគណនី ABA លេខ ០០០ ៣១០ ២២៧ (ឈ្មោះ [redacted] SORPHEA) ឬគណនី ABA លេខ ០០០ ៣៩២ ០៩៧ (ឈ្មោះ [redacted] SORPHEA)។

៥-បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបបង់សំណងជំងឺចិត្ត ការខូចខាតពេលវេលា និងសេវាផ្លូវច្បាប់ ជាប្រាក់ចំនួន ១៥ ០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) មកឱ្យដើមចោទនៃបណ្តឹងតប។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**២-ការពន្យល់ត្រួសៗអំពីអង្គហេតុ៖**

ដើមចោទឈ្មោះ [redacted] បញ្ញាសក្កដា បានរៀបអាពាហ៍ពិពាហ៍ឈ្មោះ [redacted] សោភា តាំងពីឆ្នាំ២០១៨ ដោយយើងទាំងពីរនាក់ក៏បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ផងដែរ។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះ ភាគីទាំងពីរក៏បានបង្កើតបានកូនម្នាក់គឺឈ្មោះ [redacted] ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩ ជនជាតិខ្មែរ និងមានទ្រព្យសម្បត្តិរួមជាមួយគ្នាមាន ផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៨ ភូមិវិជ្ជលជើង សង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ និងបំណុលនៅធនាគារ SINHAN BANK ចំនួន ១៨,០០០(មួយម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក។ ក្រោយពីការរស់នៅជាមួយគ្នាជាប្តីប្រពន្ធចេះតែមិនចុះសម្រុងនឹងគ្នា ចេះតែទាស់ទែងគ្នាមិនចេះចប់មិនចេះហើយ ជាហេតុធ្វើឱ្យដើមចោទឈ្មោះ [redacted] បញ្ញាសក្កដា អស់មនោសញ្ចេតនាស្រឡាញ់គ្នា ជាប្តីប្រពន្ធ ទៅអនាគតទៅទៀត។ ចំណែកឯកចុងចម្លើយឈ្មោះ [redacted] សោភា បានបញ្ជាក់ថា មូលហេតុដែលខ្លួនសុំលែងលះគឺដោយសារឈ្មោះ ប្រាជ្ញ បញ្ញាសក្កដា ធ្លាប់ប្រើហិង្សាមកលើខ្លួនដោយច្របាច់កផ្ទប់នឹងជញ្ជ យកកាំបិតមកក្នុងកខ្លួន មានស្រីថ្មី និងបោះបង់ខ្លួន និងកូន ដោយចុះចេញពីផ្ទះតាំងពីខែមិថុនា ឆ្នាំ២០២៣ រហូតមកដល់បច្ចុប្បន្ន ទើបធ្វើឱ្យឈ្មោះ [redacted] សោភា អស់មនោសញ្ចេតនាស្រឡាញ់គ្នា ជាប្តីប្រពន្ធ ទៅអនាគតទៅទៀត។

**៣-ការអះអាងរបស់ភាគី៖**

៣.១-ដើមចោទឈ្មោះ [redacted] បញ្ញាសក្កដា បានធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយថា៖ ខ្លួនសុំឲ្យតុលាការ ចេញសាលក្រមសម្រេចដូចកម្មវត្ថុខាងលើ។ ខ្លួនសុំរក្សាការថ្លែងការណ៍ដូចមាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកមុនទុកជាបានការទាំងស្រុងដដែល។

ចំពោះចំណុចវិវាទ និងការទាមទាររបស់ឈ្មោះ [redacted] សោភា ខ្លួនពុំមានលទ្ធភាពនោះទេ ព្រោះប្រាក់ខែខ្លួនបានបង់ទៅលើផ្ទះអស់ហើយ សូម្បីតែខ្លួនមិនមានប្រាក់ចាយប្រចាំខែផង។



Scanned with CamScanner

-មេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបចុងក្រោយថា៖ កូនក្តីខ្ញុំសុំរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹងតប និងពាក្យបន្ថែមពាក្យបណ្តឹងដដែល និងសុំរក្សារការថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកមុនទុកជាបានការដដែល។ ផ្អែកតាមភស្តុតាងដែលកូនក្តីនាងខ្ញុំបានដាក់ជូនតុលាការ ឃើញថាមានមូលហេតុត្រឹមត្រូវតាមមាត្រា ៩៧៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ដែលបានលើកឡើង ដូច្នេះស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់ ហើយកូនក្តីនាងខ្ញុំយល់ព្រមលែងលះជាមួយដើមចោទដែរ ដោយមូលហេតុកូនក្តីនាងខ្ញុំទទួលរងនូវអំពើជិតដែលគាត់មិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន។ ចំពោះទ្រព្យសម្បត្តិមានផ្ទះមួយល្វែង គឺផ្ទះលេខK៣០ ផ្លូវលេខ៩ ភូមិវិជ្ជលជើង សង្កាត់ស្ពោ ខណ្ឌកំបូល រាជធានីភ្នំពេញ មានតម្លៃ ៣២,០០០ (បីម៉ឺនពីរពាន់)ដុល្លារអាមេរិក ដែលដើមចោទ និងកូនក្តីនាងខ្ញុំ បានទិញផ្តាច់ ប៉ុន្តែខ្ចីលុយធនាគារបង់រំលស់ ផ្ទះនេះកូនក្តីនាងខ្ញុំ សុំប្រគល់ឱ្យដើមចោទជាអ្នកគ្រប់គ្រង ដោយកូនក្តីនាងខ្ញុំ សុំឱ្យដើមចោទប្រគល់ប្រាក់ចំនួន ២៨,០០០ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក មកឲ្យកូនក្តីនាងខ្ញុំ ជាថ្នូរនឹងការប្រគល់ផ្ទះ ព្រោះកូនក្តីនាងខ្ញុំត្រូវការប្រាក់យកមកសង់លំនៅថ្មីនៅលើដីជិតផ្ទះម្តាយរបស់គាត់ នៅឯស្រុកថ្កូងដែលជាស្រុកកំណើតរបស់គាត់ ដើម្បីអាចឲ្យកូនមានផ្ទះរស់នៅនឹងអាចឲ្យម្តាយកូនក្តីនាងខ្ញុំ។ ចំពោះសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩ កូនក្តីនាងខ្ញុំ យល់ព្រមទទួលសិទ្ធិជាអ្នកមានអំណាចមេបាលើកូនតាមដែលដើមចោទបានស្នើសុំ។ ប្រាក់ប្រដាប់ក្តីកូនក្តីនាងខ្ញុំយល់ព្រមឯកភាពតាមការស្នើសុំរបស់ដើមចោទដែរ ដូច្នេះស្នើសុំតុលាការស្រេចអំពីអំណាចមេបាតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។ ចំពោះសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន កូនក្តីនាងខ្ញុំសុំឲ្យដើមចោទបង់ប្រាក់មកឲ្យកូនក្តីនាងខ្ញុំក្នុងមួយខែចំនួន ៨០០,០០០(ប៉ែតសិបម៉ឺន)រៀល ជារៀងរាល់ខែ ដោយដាក់បញ្ចូលក្នុងគណនី ABA លេខ ០០០ ៣១០ ២២៧ (ឈ្មោះ CHHORM SORPHEA) ឬគណនី ABA លេខ ០០០ ៣៩២ ០៩៧ (ឈ្មោះ CHHORM SORPHEA) របស់ចុងចម្លើយ ព្រោះកូនក្តីនាងខ្ញុំត្រូវការចំណាយចិញ្ចឹមកូនទាំងការរៀនសូត្រ ហូបចុក ចាយវាយប្រចាំថ្ងៃ និងមើលថែទាំជម្ងឺកូនដែលមានបញ្ហា Autism ដែលជាជម្ងឺពាក់ព័ន្ធនឹងបញ្ហាខួរក្បាលស្មារតីមិនប្រក្រតី ហើយកូននេះក៏មិនអាចនិយាយស្តីបាននោះទេ ហេតុនេះត្រូវចំណាយថវិកាច្រើនក្នុងការថែទាំ និងទាំងពេលវេលា កម្លាំងកាយ កម្លាំងចិត្តក្នុងការមើលថែរក្សាកូនផងដែរ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចអំពីសោហ៊ុយចិញ្ចឹមកូនតាមការស្នើសុំរបស់កូនក្តីនាងខ្ញុំ និងតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។ ចំពោះប្រាក់ប្រដាប់ក្តីតុលាការ ខាងដើមចោទស្នើសុំជាបន្ទុករបស់គាត់ ហើយកូនក្តីនាងខ្ញុំក៏ឯកភាពយល់ព្រមដែរ ដូច្នេះស្នើសុំតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះការទាមទារសំណងការខូចខាតជាប្រាក់ចំនួន ១៥,០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ដោយហេតុថា កូនក្តីនាងខ្ញុំទទួលរងនូវវិបត្តិផ្លូវចិត្ត (សំណងជំងឺចិត្ត) ដោយសារខាងដើមចោទបានផិតក្បត់ ប្រើហិង្សា និងចុះចេញពីផ្ទះចោលប្រពន្ធកូន និងប្តឹងផ្តល់មកតុលាការ ដែលធ្វើឱ្យកូនក្តីនាងខ្ញុំចំណាយលើសេវាកម្មផ្លូវច្បាប់ផងដែរ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចអំពីសំណងនេះតាមមាត្រា ១១ និងមាត្រា ១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងហានៈបុគ្គល។

-មេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបចុងក្រោយថា៖ ខ្លួនឯកភាពតាមការថ្លែងការណ៍របស់សហភាតាខាងលើដែរ។

-មេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបចុងក្រោយថា៖ នាងខ្ញុំ ឯកភាពតាមការថ្លែងការណ៍របស់សហភាគាខាងលើដែរ។

**៤-ការប្រាស្រ័យទាក់ទង**

ការប្រាស្រ័យទាក់ទងកូន ភាគីដើមចោទ និងចុងចម្លើយមិនបានពិភាក្សាគ្នា អំពីការចូលជួបប្រាស្រ័យទាក់ទងកូននោះទេ។ ដូច្នេះ តម្រូវតុលាការពិចារណា និងសម្រេចសេចក្តីឱ្យអ្នកដែលមិនមានសិទ្ធិអំណាចមេបាលើកូន អាចចូលជួបប្រាស្រ័យទាក់ទងកូនបានតាមការពិភាក្សាគ្នា និងភាគីដែលមានសិទ្ធិអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលគ្មានសិទ្ធិអំណាចមេបាលើកូន ក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន។

**៥-ឯកសារភស្តុតាងដែលភាគីដាក់ជូនតុលាការពិនិត្យ**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ១៣ សៀវភៅអាពាហ៍ពិពាហ៍លេខៈ ០១/២០១៨ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨។

-សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ សៀវភៅកំណើតលេខៈ ០៤/២០១៩ សំបុត្រកំណើតលេខៈ ១៦០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ឧមានាថ។

-លិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យលេខ ៣៣០០៩ អពដ.ឧទអ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ។

-កិច្ចសន្យាបន្ថែមប្រាក់លេខ ០០២៨០៥ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-កិច្ចសន្យាលក់ដី-ផ្ទះលេខ ០០០៦៦៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-កិច្ចសន្យាលក់ដី-ផ្ទះលេខ ០០០៣៥១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-កិច្ចសន្យាលក់ផ្តាច់លេខ ១៧៣២/២០២០ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-តារាងប្រាក់ខែធនាគារកាណាឌីយ៉ា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-តារាងបង់រំលោះប្រាក់ ធនាគារ SHINHAN BANK ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] បញ្ញាសក្កដា។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០៨៧៧៧៥៨ (០១) ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សោភា។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១៩០៨១៤-១០០៨ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០។

-រូបភាពទាំង២៧សន្លឹក។

-ហ្លាសចំនួនមួយ។

**៦-ចំណុចគ្មានវិវាទ និងចំណុចវិវាទ**

៦.១-ចំណុចគ្មានវិវាទ៖ ភាគីដើមចោទ និងចុងចម្លើយ បានយល់ព្រមលែងលះគ្នាដូចដែលបានអះអាងខាងលើ។ ចំពោះសិទ្ធិអំណាចមេបាលើកូន ភាគីដើមចោទ និងចុងចម្លើយ បានឯកភាពគ្នាដូចដែលបានអះអាងខាងលើ។ ចំពោះប្រាក់ប្រដាប់ក្ដី ភាគីដើមចោទ និងចុងចម្លើយ បានឯកភាពគ្នាដូចដែលបានអះអាងខាងលើ។

៦.២-ចំណុចវិវាទ៖

-តើមានមូលហេតុត្រឹមត្រូវក្នុងការលែងលះដែរឬទេ?

-តើកំណត់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាពឬចំនួន៨០ម៉ឺនរៀលក្នុងមួយខែ?

-តើផ្ទះលេខK៣០ ផ្លូវលេខ៤ ភូមិវៀលជើង សង្កាត់ស្ពោ ខណ្ឌកំបូល រាជធានីភ្នំពេញ គឺមានតម្លៃសរុប ៣២,០០០ (បីម៉ឺនពីរពាន់)ដុល្លារអាមេរិក ជាទ្រព្យរួមគ្នា ត្រូវប្រគល់ឱ្យចុងចម្លើយ ឬផ្ទះខាងលើត្រូវប្រគល់ឱ្យដើមចោទ ដោយដើមចោទត្រូវប្រគល់ប្រាក់ចំនួន ២៨,០០០ (ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ជាថ្នូរមកឱ្យចុងចម្លើយ?

-តើការទាមទារសំណងការខូចខាតចំនួន ១៥,០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិករបស់ចុងចម្លើយមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរទេ?

## សំអាងហេតុ

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក ឃើញថា៖

១-ពាក្យបណ្ដឹងលែងលះលេខ: ១៧៨៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ និងពាក្យបណ្ដឹងតបលេខ: ២៦៦៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] លាងហេង តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-តាមសេចក្ដីថ្លែងការណ៍របស់គូភាគី និងការពិនិត្យភស្តុតាងជាឯកសារដែលមានក្នុងសំណុំរឿងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

២.១-ឈ្មោះ [redacted] បញ្ញាសក្ដដា និងឈ្មោះ [redacted] សោភា ពិតជាបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋានស្រុកថ្ពង ខេត្តកំពង់ស្ពឺ ត្រឹមត្រូវតាមច្បាប់ប្រាកដមែន។ ហើយការរស់នៅរបស់ដើមចោទ និងចុងចម្លើយ ក្រោយពីរៀបការរួច ការរស់នៅជាមួយគ្នាជា ប្ដីប្រពន្ធចេះតែមិនចុះសម្រុងនឹងគ្នា ចេះតែទាស់ទែងគ្នាមិនចេះចប់មិនចេះហើយ។ ចំណែកឯឈ្មោះ [redacted] សោភា បានបញ្ជាក់ថា មូលហេតុដែលខ្លួនសុំលែងលះគឺដោយសារឈ្មោះ ប្រាជ្ញ បញ្ញាសក្ដដា ធ្លាប់ប្រើហិង្សាមកលើខ្លួនដោយច្របាច់កផ្ទប់នឹងឥដ្ឋ យកកាំបិតមកភ្ជុងកខ្លួន មានស្រីថ្មី និងបោះបង់ខ្លួន និងកូន ដោយចុះចេញពីផ្ទះតាំងពីខែមិថុនា ឆ្នាំ២០២៣ រហូតមកដល់បច្ចុប្បន្ន ទើបធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាស្រឡាញ់គ្នា ជាប្ដីប្រពន្ធ។ តុលាការយល់ឃើញថាទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចសះជាឡើងវិញបានឡើយ។

២.២-អ្នកមានសិទ្ធិអំណាចមេបា ចំពោះកូនម្នាក់ឈ្មោះ [redacted] ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩ ភាគីដើមចោទយល់ព្រមប្រគល់សិទ្ធិអំណាចមេបាទៅឱ្យចុងចម្លើយ ហើយភាគីចុងចម្លើយក៏ទទួលយល់ព្រមតាមការទាមទារនេះដែរ។ ដោយពិចារណាទៅលើ ផលប្រយោជន៍



Scanned with CamScanner

របស់កូន តុលាការយល់ឃើញថា ភាគីឈ្មោះ [redacted] សោភា មានពេលវេលា និងលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនបានល្អជាងភាគីឈ្មោះ [redacted] បញ្ញាសក្កដា គប្បីតុលាការសម្រេចប្រគល់សិទ្ធិអំណាចមេបាលើកូនម្នាក់ខាងលើ។

**២.៣-សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន** ភាគីដើមចោទ និងចុងចម្លើយ មិនបានព្រមព្រៀងគ្នាចំពោះសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូននោះទេ ដោយភាគីឈ្មោះ [redacted] បញ្ញាសក្កដា ស្នើសុំផ្តល់សោហ៊ុយចិញ្ចឹមកូនទៅតាមលទ្ធភាពដែលខ្លួនមានជាប្រចាំខែរហូតដល់កូនទទួលបាននីតិភាព ប៉ុន្តែភាគីឈ្មោះ [redacted] សោភា ស្នើសុំទាមទារសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូន ពីភាគីឈ្មោះ [redacted] បញ្ញាសក្កដា ចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន)រៀល ក្នុងមួយខែជារៀងរាល់ខែមកឱ្យខ្លួនតាមរយៈគណនី ABA លេខ ០០០ ៣១០ ២២៧ (ឈ្មោះ [redacted] SORPHEA) ឬគណនី ABA លេខ ០០០ ៣៤២ ០៩៧ (ឈ្មោះ [redacted] SORPHEA)។ តុលាការយល់ឃើញថា ដើម្បីកំណត់ឱ្យបានច្បាស់លាស់ក្នុងការផ្តល់សោហ៊ុយចិញ្ចឹមកូន គប្បីតុលាការសម្រេចតាមច្បាប់លើការផ្តល់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

**២.៤-ការបែងចែកទ្រព្យសម្បត្តិ:** ចំពោះទ្រព្យសម្បត្តិរួម គឺមាន ផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៥ភូមិរំដួលជើង សង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ និងបំណុលនៅធនាគារ SINHAN BANK ចំនួន ១៨,០០០(មួយម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ភាគីឈ្មោះ [redacted] បញ្ញាសក្កដា បានអះអាងថា ខ្លួនយល់ព្រមប្រគល់ផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៥ភូមិរំដួលជើង សង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ ឱ្យទៅភាគីឈ្មោះ [redacted] សោភា ហើយខ្លួនយល់ព្រមបង់បំណុលនៅធនាគារ SINHAN BANK ចំនួន ១៨,០០០(មួយម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក រយៈពេល៧ទៀត។ ចំណែកឯភាគីឈ្មោះ [redacted] សោភា បដិសេធមិនទទួលយកផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៥ភូមិរំដួលជើង សង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ នោះទេ ដោយអះអាថាខ្លាចភាគីឈ្មោះ [redacted] បញ្ញាសក្កដា គ្មានលទ្ធភាពបង់ផ្ទះទៅថ្ងៃអានាគត និងខ្លាចមានការរឹបអូសផ្ទះនេះក្នុងករណីមិនបានបង់ប្រាក់ ដូច្នេះភាគីឈ្មោះ [redacted] សោភា ប្រគល់ផ្ទះខាងលើឱ្យទៅឈ្មោះ [redacted] បញ្ញាសក្កដា ជាអ្នកទទួល និងរ៉ាប់រងបង់ខ្លួនឯងដោយខ្លួនទាមទារជាប្រាក់ពីភាគីឈ្មោះ [redacted] បញ្ញាសក្កដា ចំនួន ២៨,០០០ (ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ជាថ្នូរនឹងការប្រគល់ផ្ទះខាងលើឱ្យទៅភាគីឈ្មោះ [redacted] បញ្ញាសក្កដា។ តុលាការយល់ឃើញថា ភាគីមិនមានការព្រមព្រៀងគ្នាក្នុងការបែងចែកទ្រព្យខាងលើនេះទេ គប្បីតុលាការពិចារណា និងសម្រេចសេចក្តីតាមច្បាប់។

**២.៥-តុលាការកំណត់អំពីអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី** ដើម្បីជៀសវាងការប្រកួតប្រជែងទាក់ទងនឹងការសន្មត់បិតុភាពរបស់កូន ផ្អែកតាមបញ្ញត្តិមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី អំឡុងពេលប្រកួតប្រជែងគ្នានេះ គឺ១២០ថ្ងៃ។ ដូច្នេះការរៀបអាពាហ៍ពិពាហ៍ថ្មីនៅក្នុងអំឡុងនេះត្រូវបានកំរិត។

**២.៦-ភាគីឈ្មោះ** [redacted] សោភា ស្នើសុំ បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបបង់សំណងជំងឺចិត្ត ការខូចខាតពេលវេលា និងសេវាផ្លូវច្បាប់ ជាប្រាក់ចំនួន ១៥ ០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាចមេរិក) មកឱ្យដើមចោទនៃបណ្តឹងតប។ ចំណែកឯភាគីឈ្មោះ [redacted] បញ្ញាសក្កដា បានអះ



Scanned with CamScanner

អាងថា ខ្លួនមិនមានលទ្ធភាពបង់សងនោះទេ ព្រោះខ្លួននៅជាប់បន្ទុកបង់ផ្ទះ និងគ្មានប្រាក់ចិញ្ចឹមខ្លួនឯងផង។ តុលាការឃើញថា ក្នុងរឿងលែងលះនេះភាគីទាំងសងខាងគឺទទួលរងនូវការប៉ះទង្គិចអារម្មណ៍ផ្លូវចិត្តរៀងៗខ្លួន ហើយក៏មិនមានការខូចខាត ឬខាតបង់ផលប្រយោជន៍ធ្ងន់ធ្ងរនោះទេ។ ដូច្នេះការស្នើសុំនេះពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យតុលាការពិចារណានោះទេ គប្បីតុលាការច្រានចោលការទាមទារសំណងនេះរបស់ភាគីឈ្មោះ [redacted] សោភា។

**៣-កំណត់អំពីរបៀបចូលជួប និងការប្រាស្រ័យទាក់ទងកូន**

ដើមចោទ និងចុងចម្លើយ មិនបានពិភាក្សាគ្នាទេក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន។ តុលាការយល់ឃើញថា ចំពោះការប្រាស្រ័យទាក់ទងកូន ភាគីដែលជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ត្រូវបង្កឱ្យមានលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន។ គប្បីតុលាការពិចារណា និងសម្រេចសេចក្តីតាមបញ្ញត្តិមាត្រា ១០៤០ ចំណុច៦ នៃក្រមរដ្ឋប្បវេណី។

៤-ភាគីឈ្មោះ [redacted] បញ្ញាសក្កដា បានស្នើសុំទទួលជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីផ្សេងៗ ដូច្នេះគប្បីតុលាការសម្រេច អំពីការទទួលបន្ទុកប្រាក់ប្រដាប់ក្តីផ្សេងៗតាមការស្នើសុំ និងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

**១-ឱ្យដើមចោទឈ្មោះ** [redacted]បញ្ញាសក្កដា លែងលះពីចុងចម្លើយឈ្មោះ [redacted]សោភា។

-ឱ្យភាគីចុងចម្លើយឈ្មោះ [redacted]សោភា ស្ថិតនៅក្នុងភាពជាមេម៉ាយរយៈពេល ១២០ថ្ងៃ គិតពីថ្ងៃអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។

**២-ឱ្យចុងចម្លើយឈ្មោះ** [redacted]សោភា ជាមានសិទ្ធិអំណាចមេបាលើកូនម្នាក់ឈ្មោះ [redacted] ឧមានាថ កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩។

**របៀបប្រាស្រ័យទាក់ទងកូន:** អ្នកដែលមិនមានសិទ្ធិអំណាចមេបាលើកូន អាចចូលជួបប្រាស្រ័យទាក់ទងកូនបានតាមការពិភាក្សាគ្នា និងភាគីដែលមានសិទ្ធិអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលគ្មានសិទ្ធិអំណាចមេបាលើកូន ក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន។

**៣-បង្គាប់ឱ្យដើមចោទឈ្មោះ** [redacted]បញ្ញាសក្កដា ផ្តល់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនជាប្រាក់ចំនួន ៦០០,០០០៛ (ហុកសិបម៉ឺន)រៀល ជារៀងរាល់ខែឱ្យទៅចុងចម្លើយឈ្មោះ [redacted] សោភា រហូតដល់កូនទទួលបាននីតិភាព។

**៤-បង្គាប់ឱ្យដើមចោទឈ្មោះ** [redacted] បញ្ញាសក្កដា ប្រគល់ប្រាក់ចំនួន ២៨,០០០$ (ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ឱ្យទៅភាគីចុងចម្លើយឈ្មោះ [redacted] សោភា។

**៥-ឱ្យដើមចោទឈ្មោះ** [redacted]បញ្ញាសក្កដា មានសិទ្ធិកម្មសិទ្ធិគ្រប់គ្រងលើផ្ទះមួយល្វែងទំហំ ៥ម៉ែត្រ គុណនឹង ១០ម៉ែត្រ ស្ថិតនៅផ្ទះលេខK៣០ ផ្លូវលេខ៩ភូមិវិថ្លូលជើង សង្កាត់ស្ពោ ខណ្ឌកំបូល រាជធានីភ្នំពេញ។

៦-ច្រានចោលការទាមទារសំណង់ក្នុងចំណុចទី៥នៃកម្មវត្ថុបណ្តឹងតបខាងលើ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។



Scanned with CamScanner

៨-សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ និងប្រកាសសាលក្រមនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ចំពោះមុខដើមចោទ និងចុងចម្លើយ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ០៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កំពង់ស្ពឺ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

Scanned with CamScanner